**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ✓

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការរៀបចំកិច្ចប្រជុំក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បី សម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងសាធារណជនជាតិ និងអន្តរជាតិជ្រាបថា កន្លងមក ក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល បានរៀបចំកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ចំនួន៦លើក ជាមួយតំណាងអង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់ពីគោលបំណង និងហេតុផលក្នុងការលើកសំណើសុំធ្វើវិសោធនកម្មចំនួន១៧មាត្រា នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ជាលទ្ធផល នៃកិច្ចប្រជុំនេះបានពិភាក្សា និងពិគ្រោះយោបល់ លើមាត្រាចំនួន១៤ រួមមាន៖ មាត្រា១ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា២០ មាត្រា២៤ មាត្រា២៥ មាត្រា២៦ មាត្រា៣០ មាត្រា៣១ មាត្រា៣២ និងមាត្រា៣៥។ ដោយឡែក មាត្រាចំនួន៣ គឺ មាត្រា៣ មាត្រា៤ និងមាត្រា២៧ តំណាងអង្គការសង្គមស៊ីវិលបានស្នើសុំរក្សាទុកនូវខ្លឹមសារដើមដដែល។

លើមូលដ្ឋាននេះ ក្រុមការងាររបស់រាជរដ្ឋាភិបាលនឹងរៀបចំកិច្ចប្រជុំ នៅថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង៨:៣០ នាទីព្រឹក នៅសាលប្រជុំ "អគារ៥" ទីស្តីការក្រសួងមហាផ្ទៃខាងមុខនេះ ដើម្បីពិនិត្យលើខ្លឹមសារ នៃមាត្រាទាំង១៤ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានស្នើសុំធ្វើវិសោធនកម្មដោយតំណាងអង្គការសង្គមស៊ីវិល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ព្រមទាំងសាធារណជនជាតិ និងអន្តរជាតិមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ...អង្គារ ៧កើត...ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.២៥. ខែសីហា ឆ្នាំ ២០២០
**ក្រសួងមហាផ្ទៃ**

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh